ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ១៧៦ / ស.ជ.ក / ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសនិស្សិត សិស្ស ប្រឡងចូលសិក្សាវគ្គនាយទាហានសកម្មជំនាន់ទី២២ នាយទាហានទ័ពជើងគោកជំនាន់ទី១០ នាយទាហានបន្តវេនជំនាន់ទី១១ និងនាយទាហានជំនាញបច្ចេកទេសយោធា

**យោង** - បានឃើញប្រកាសលេខ ០៥២/ប្រ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងការពារជាតិ ស្តីពីការបង្កើតគណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស។

- បានឃើញប្រកាសលេខ ០៥៩-០៦០-០៦១/ប្រ.ក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើស និងហ្វឹកហ្វឺន នាយទាហានសកម្មជំនាន់ទី២២ នាយទាហានទ័ពជើងគោកជំនាន់ទី១១ និងនាយទាហានបន្តវេនជំនាន់ទី១១ ។
- បានឃើញប្រកាសលេខ ០៥០/ប្រ.ក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើសនិស្សិត សិស្សមកបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន

ប្រធានគណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស សូមជូនដំណឹងដល់បេក្ខជននិស្សិត សិស្សទាំងពីរភេទ ដែលស្ម័គ្រចិត្តចូលបំរើការងារក្នុងក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ត្រូវមកទំនាក់ទំនងដាក់ពាក្យសុំចុះឈ្មោះចូលប្រឡងជ្រើសរើស វគ្គនាយទាហានសកម្មជំនាន់ទី២២ នាយទាហានទ័ពជើងគោកជំនាន់ទី១០ នាយទាហានបន្តវេនជំនាន់ទី១១ និងនាយទាហានជំនាញបច្ចេកទេសយោធា ដូចមានលក្ខខ័ណ្ឌជ្រើសរើសនិងកាលបរិច្ឆេទ ខាងក្រោម៖

### ក.លក្ខខ័ណ្ឌជ្រើសរើស

១.សញ្ជាតិខ្មែរ

២.មានអាយុពី ១៨ ឆ្នាំ ដល់ ២៥ ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង

៣.មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

៤.មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

៥.មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ

៦.បុរសមានកំពស់ ១,$^{ម}$៦០ និងនារីមានកំពស់ ១,$^{ម}$៥០ ឡើងទៅ

៧.មានលិខិតបញ្ជាក់កិរិយាមាយាទពីមូលដ្ឋាន ឃុំ ឬសង្កាត់។

### ខ.កាលបរិច្ឆេទ

-ចាប់ផ្តើមចែកពាក្យនិងទទួលពាក្យសុំចុះឈ្មោះចូលប្រឡងពីថ្ងៃទី២៦ ខែកញ្ញា ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧

-ទីកន្លែងចែក និងទទួលពាក្យ នៅសាកលវិទ្យាល័យការពារជាតិ និងនៅយោធភូមិភាគទី ១ ទី២ ទី៣ ទី៤ ទី៥ សូមទំនាក់ទំនងតាមរយៈ វិបសាយ អ៊ីម៉ែល ទូរស័ព្ទលេខ៖

- វិបសាយ WWW : cot.mod.gov.kh (Facebook): RCAF Cambodia

- អ៊ីម៉ែល Email : cotcambodia@mod.gov.kh

- ទូរស័ព្ទលេខ ០៨៦ ៨៤ ៧៣ ៥៥ / ០៨៨ ៥៥ ៨៨ ០៧៤ / ០១១ ៥៨ ២៤ ០០

សូមអញ្ជើញបេក្ខជននិស្សិត សិស្សទាំងពីរភេទ មកទំនាក់ទំនងសាកសួរព័ត៌មានលម្អិត និងបំពេញទម្រង់បែបបទផ្សេងៗ នៅទីកន្លែងដាក់ពាក្យ នៅរៀងរាល់ម៉ោងធ្វើការ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៧

**អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ**

**និងជាប្រធានគណៈកម្មការ**

នាយឧត្តមសេនីយ៍.គួង_ស៊ីផាន